**បទឃាតកម្ម (murder)**

បទឃាតកម្ម ជាបទឧក្រិដ្ឋក្រោមច្បាប់ជាតិ និងអន្តរជាតិ (international law)។ បទល្មើសនេះមានធាតុផ្សំចំនួនបី៖ ១. ជនរងគ្រោះស្លាប់ (victim)។ ២. ការស្លាប់ដោយសារ ទង្វើ ឬការខកខាន (act and omission) និងទី៣ ធ្វើឡើងក្នុងចេតនាសម្លាប់ (intent) ឬបានបង្ករបួសស្នាមធ្ងន់ធ្ងរ ដែលជនល្មើស បានដឹងសមហេតុសមផលថា ជនរងគ្រោះទំនងនឹងស្លាប់ (*Krnojelac*, IT-97-25-T, 2000, S. 324)។

យុត្តិសាស្ត្រ មិនបានទាមទារភស្តុតាងបង្ហាញសាកសពរបស់ជនរងគ្រោះ ដើម្បីដាក់ឲ្យជនល្មើសទទួលខុសត្រូវទេ។ ក៏ប៉ុន្តែ មានការតម្រូវឲ្យមានចំណងហេតុនិងផល (causation)។ ទង្វើចៃដន្យបង្កឲ្យជនរងគ្រោះស្លាប់ នឹងមិនមែនជាបទឃាតកម្មទេ ដោយសារ ធាតុផ្សំអត្តនោម័តនៃបទល្មើសនេះ ទាមទារនូវចេតនា។ និយាយម្យ៉ាងទៀត ការធ្វេសប្រហែស (negligence) ឬសូម្បីការខ្ជីខ្ជា (recklessness) ក៏មិនគ្រប់គ្រាន់ ប្រសិន មិនចូលក្នុងកម្រិតអត្តនោម័ត ដូចបានរៀបរាប់ខាងលើ។ ការដឹងថាមានកម្រិតហានិភ័យនៃការស្លាប់ខ្ពស់ ឬ ការស្លាប់ដែលជាផលវិបាក អាចកើតមានឡើង ទើបអាចបំពេញកម្រិតនៃធាតុផ្សំអត្តនោម័តនៃបទល្មើសនេះ។

ធាតុផ្សំនៃបទឃាតកម្ម និង ការសម្លាប់ដោយចេតនា (willful killing) មានដូចគ្នា ហើយបទឃាតកម្ម ក្រោមបទឧក្រិដ្ឋកម្មសង្គ្រាម (war crime) និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity) ក៏មានធាតុផ្សំដូចគ្នាផងដែរ លើកលែងតែធាតុផ្សំរួមនៃបទឧក្រិដ្ឋទាំងពីរនេះ (chapeau elements)( Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 426-427)។